Minnesota Department of Education

# សេចក្តីណែនាំរបស់ឪពុកម្តាយ/អាណាព្យាបាល អំពីការធ្វើតេស្តទូទាំងរដ្ឋ

ឯកសារនេះផ្តល់ជូននូវព័ត៌មានមូលដ្ឋានមួយចំនួនដើម្បីឪពុកម្តាយ/អាណាព្យាបាលធ្វើការសម្រេចបានដោយមានព័ត៌មានគ្រប់គ្រាន់ដែលផ្តល់ផលប្រយោជន៍ដល់កូនរបស់ពួកគេ និងសាលារៀន និងសហគមន៍របស់ពួកគេ។

## ហេតុអ្វីធ្វើតេស្តទូទាំងរដ្ឋ?

មីនីសូតាផ្តល់តម្លៃដល់ប្រព័ន្ធអប់រំរបស់ខ្លួន និងភាពជំនាញរបស់អ្នកផ្តល់ការអប់រំរបស់ខ្លួន។ អ្នកផ្តល់ការអប់រំរបស់មីនីសូតាបានបង្កើតស្តង់ដារនៃការសិក្សាដែលមានភាពតឹងរ៉ឹង និងត្រៀមខ្លួនសិស្សានុសិស្សរបស់យើងសម្រាប់អាជីពការងារ និងការសិក្សាថ្នាក់មហាវិទ្យាល័យ។

ការវាយតម្លៃទូទាំងរដ្ឋ គឺជាវិធីដែលយើង ក្នុងនាមជារដ្ឋមួយ ធ្វើការវាស់វែងថាស្តង់ដារនៃការសិក្សាមានលក្ខណៈស្របគ្នាជាមួយកម្មវិធីសិក្សា និងការណែនាំប្រចាំថ្ងៃនៅក្នុងសាលារៀនរបស់យើងដែរ ដោយធានាថាសិស្សានុសិស្សគ្រប់រូបត្រូវបានផ្តល់ជូននូវការអប់រំដែលមានសមធម៌។ លទ្ធផលនៃការវាយតម្លៃទូទាំងរដ្ឋគឺជាវិធីសាស្ត្រមួយផ្សេងទៀតក្នុងការពិនិត្យតាមដានថា យើងកំពុងផ្តល់ជូនក្មេងៗរបស់យើងនូវការអប់រំដែលធានាបាននូវកម្លាំងពលកម្មដ៏ខ្លាំងក្លា និងប្រជាពលរដ្ឋដែលមានចំណេះដឹងខ្ពស់។

## ស្តង់ដារនៃការសិក្សា និងការវាយតម្លៃ

### តើស្តង់ដារនៃការសិក្សា គឺជាអ្វី?

ស្តង់ដារនៃការសិក្សា K–12 របស់មីនីសូតា គឺជាការរំពឹងទុកនូវសេចក្តីសម្រេចរបស់សិស្សានុសិស្សនៅទូទាំងរដ្ឋ។ ស្តង់ដារទាំងនេះសម្គាល់ចំណេះដឹង និងជំនាញដែលសិស្សានុសិស្សគ្រប់រូបត្រូវតែសម្រេចឲ្យបាននៅក្នុងខ្លឹមសារណាមួយនៅពេលបញ្ចប់ថ្នាក់រៀនកម្រិតណាមួយ។ ស្រុកសាលារៀនកំណត់អំពីវិធីដែលសិស្សានុសិស្សទាំងឡាយនឹងបំពេញតាមស្តង់ដារនានាតាមរយៈការអភិវឌ្ឍវគ្គសិក្សា និងកម្មវិធីសិក្សា។

### តើទំនាក់ទំនងរវាងការវាយតម្លៃការសិក្សាទូទាំងរដ្ឋ និងស្តង់ដារនៃការសិក្សា គឺជាអ្វី?

ការវាយតម្លៃទូទាំងរដ្ឋផ្នែកគណិតវិទ្យា ការអាន និងវិទ្យាសាស្ត្រ ត្រូវបានប្រើប្រាស់ដើម្បីវាស់កម្រិតថាតើសិស្សានុសិស្ស និងសាលារៀន និងស្រុកសាលារៀនរបស់ពួកគេ បានបំពេញតាមស្តង់ដារនៃការសិក្សាដែរឬទេ។ ការវាយតម្លៃទូទាំងរដ្ឋ គឺជាវិធីសាស្ត្រមួយដើម្បីវាស់ថាតើសិស្សានុសិស្សធ្វើបានល្អដល់កម្រិតណាចំពោះខ្លឹមសារដែលជាផ្នែកមួយនៃការណែនាំប្រចាំថ្ងៃរបស់ពួកគេ។ វាក៏ជាវិធីមួយដើម្បីវាស់ថាតើសាលារៀន និងស្រុកសាលារៀនកំពុងអនុវត្តស្របតាមកម្មវិធីសិក្សា និងការបង្រៀនតាមស្តង់ដារបានល្អដល់កម្រិតណាផងដែរ។

### ការវាយតម្លៃគ្រប់ជ្រុងជ្រោយរបស់មីនីសូតា (MCA) និងការធ្វើតេស្តជំនាញសិក្សារបស់មីនីសូតា (MTAS)

- ផ្អែកតាមស្តង់ដារនៃការសិក្សារបស់មីនីសូតា
- ផ្តល់ជូនជារៀងរាល់ឆ្នាំចាប់ថ្នាក់ទី 3–8 និងនៅវិទ្យាល័យសម្រាប់មុខវិជ្ជាការអាន និងគណិតវិទ្យា; ផ្តល់ជូនជារៀងរាល់ឆ្នាំសម្រាប់ថ្នាក់ទី 5, ថ្នាក់ទី 8, និងនៅវិទ្យាល័យសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ
- សិស្សានុសិស្សភាគច្រើនធ្វើ MCA
- MTAS គឺជាជម្រើសមួយសម្រាប់សិស្សានុសិស្សដែលអសមត្ថភាពផ្នែកប្រាជ្ញាធ្ងន់ធ្ងរបំផុត

### ACCESS និង ACCESS ជំនួសសម្រាប់អ្នករៀនភាសាអង់គ្លេស

- ផ្អែកតាមស្តង់ដារអភិវឌ្ឍភាសាអង់គ្លេសរបស់ WIDA
- ផ្តល់ជូនជារៀងរាល់ឆ្នាំសម្រាប់អ្នករៀនភាសាអង់គ្លេសចាប់ពីថ្នាក់ K–12 សម្រាប់មុខវិជ្ជាការអាន ការសរសេរ ការស្តាប់ និងការនិយាយ
- អ្នករៀនភាសាអង់គ្លេសភាគច្រើនធ្វើតេស្ត ACCESS សម្រាប់ ELLs
- ACCESS ជំនួសសម្រាប់ ELLs គឺជាជម្រើសមួយសម្រាប់អ្នករៀនភាសាអង់គ្លេសដែលអសមត្ថភាពផ្នែកប្រាជ្ញាធ្ងន់ធ្ងរបំផុត

## តើត្រូវចំណាយពេលប៉ុន្មានលើការធ្វើតេស្តទូទាំងរដ្ឋ?

ការវាយតម្លៃទូទាំងរដ្ឋត្រូវបានធ្វើឡើងរៀងរាល់មួយឆ្នាំម្តង សិស្សានុសិស្សភាគច្រើនធ្វើតេស្តតាមប្រព័ន្ធអ៊ីនធឺណិត។ ជាមធ្យម ពេលវេលាដែលត្រូវចំណាយលើការវាយតម្លៃទូទាំងរដ្ឋ គឺ **តិចជាងមួយភាគរយនៃម៉ោងផ្តល់ការណែនាំ** នៅក្នុងមួយឆ្នាំសិក្សា។ ការវាយតម្លៃមិនត្រូវបានកំណត់ពេលវេលាទេ ហើយសិស្សានុសិស្សអាចបន្តធ្វើការងារ ដរាបណាពួកគេត្រូវការធ្វើដូច្នោះ។

## តើសិស្សានុសិស្សធ្វើតេស្តវាយតម្លៃនៅពេលណា?

សាលារៀននីមួយៗកំណត់កាលវិភាគនៃការធ្វើតេស្តរបស់ពួកគេនៅក្នុងកាលវិភាគនៃការធ្វើតេស្តរបស់រដ្ឋ។ ចូរទាក់ទងសាលារៀនរបស់សិស្សានុសិស្សរបស់អ្នកសម្រាប់ព័ត៌មានស្តីពីថ្ងៃធ្វើតេស្តជាក់លាក់។

- កាលវិភាគនៃការធ្វើតេស្ត MCA និង MTAS ចាប់ផ្តើមពីខែមីនា និងបញ្ចប់នៅខែឧសភា។
- កាលវិភាគនៃការធ្វើតេស្ត ACCESS និង ACCESS ជំនួសសម្រាប់ ELLs ចាប់ផ្តើមនៅចុងខែមករា និងចុងខែមីនា។

## ហេតុអ្វីបានជាការវាយតម្លៃទាំងនេះមានប្រសិទ្ធភាព?

មីនីសូតា ជឿជាក់ថា ដើម្បីវាស់កម្រិតអំពីអ្វីដែលសិស្សានុសិស្សកំពុងរៀនប្រកបដោយប្រសិទ្ធភាព ការធ្វើតេស្តចាំបាច់ត្រូវលើសពីការសួរសំណួរដែលមានជម្រើសច្រើន។

- ដើម្បីឆ្លើយតបនឹងសំណួរនានា សិស្សានុសិស្សអាចត្រូវចាំបាច់ត្រូវវាយអក្សរ ទាញ និងទម្លាក់រូបភាព និងពាក្យនានា ឬប្រើប្រាស់ក្រាហ្វ ឬព័ត៌មាន។
- MCA សម្រាប់មុខវិជ្ជានៃការអាន និងគណិតវិទ្យាអាចសម្របតាមគ្នាបាន មានន័យថាចម្លើយដែលសិស្សផ្តល់ជូននឹងកំណត់សំណួរបន្ទាប់ដែលសិស្សនឹងឆ្លើយតប។
- MCA សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ រួមបញ្ចូលការបង្កើតនានា ដែលតម្រូវឲ្យសិស្សានុសិស្សធ្វើការពិសោធន៍ដើម្បីឆ្លើយតបនឹងសំណួរនានា។

ចំណុចទាំងអស់នេះផ្តល់សិស្សានុសិស្សនូវឱកាសក្នុងការប្រើប្រាស់ការគិត និងការវិភាគគ្រប់ជ្រុងជ្រោយដែលចាំបាច់ដើម្បីទទួលបានភាពជោគជ័យនៅកម្រិតមហាវិទ្យាល័យ និងអាជីពការងារ និងបង្ហាញអំពីអ្វីដែលពួកគេបានដឹង និងអាចធ្វើបាន។

ដោយសារតែខ្លឹមសារនៃតេស្តតំណាងឲ្យស្តង់ដារឲ្យបានពេញលេញជាទីបំផុតតាមដែលអាចធ្វើទៅបាននោះ ការរៀបចំសម្រាប់ និងការធ្វើការវាយតម្លៃ ប្រើប្រាស់ចំណេះដឹង ដំណើរការ និងយុទ្ធសាស្ត្រដូចគ្នាទៅនឹងចំណេះដឹង ដំណើរការ និងយុទ្ធសាស្ត្រនានាដែលត្រូវបានប្រើប្រាស់នៅក្នុងថ្នាក់រៀនដែលល្អបំផុតផងដែរ។

## តើខ្ញុំទទួលបានលទ្ធផលរបស់សិស្សរបស់ខ្ញុំនៅពេលណា?

នៅរៀងរាល់រដូវក្តៅ របាយការណ៍របស់សិស្សានុសិស្សម្នាក់ៗនឹងត្រូវបានបញ្ជូនទៅកាន់ស្រុកសាលារៀន និងត្រូវបានផ្តល់ជូនក្រុមគ្រួសារមិនយូរជាងពេលបើកសន្និសិទនៅរដូវស្លឹកឈើជ្រុះឡើយ។ របាយការណ៍នានអាចត្រូវបានប្រើប្រាស់ដើម្បីមើលឃើញនូវវឌ្ឍនភាពរបស់កូនរបស់អ្នក និងជួយផ្តល់ការណែនាំសម្រាប់ពេលអនាគតផងដែរ។

## ចុះប្រសិនបើខ្ញុំជ្រើសរើសមិនឲ្យសិស្សរបស់ខ្ញុំចូលរួម?

បទប្បញ្ញត្តិរបស់មីនីសូតាតម្រូវឲ្យ MDE ធ្វើការបោះពុម្ពផ្សាយនូវទម្រង់បែបបទមួយសម្រាប់ឲ្យឪពុកម្តាយ/អាណាព្យាបាលបំពេញ ប្រសិនបើពួកគេបដិសេធមិនឲ្យសិស្សរបស់ពួកគេចូលរួមនៅក្នុងការវាយតម្លៃកម្រិតស្តង់ដារដែលត្រូវបានតម្រូវដោយរដ្ឋនោះ។ ទម្រង់បែបបទដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់នេះ អាចស្វែងរកបាននៅលើគេហទំព័ររបស់ MDE នៅតាមតំណភ្ជាប់ខាងក្រោម។ ស្រុកសាលារៀនរបស់សិស្សរបស់អ្នកអាចត្រូវការព័ត៌មានបន្ថែម។

## ហេតុអ្វីបានជាការចូលរួមមានសារៈសំខាន់?

ការវាយតម្លៃទូទាំងរដ្ឋ គ្រាន់តែជាវិធីសាស្ត្រមួយក្នុងការវាស់ស្ទង់អំពីការសម្រេចបានរបស់សិស្សរបស់អ្នកតែប៉ុណ្ណោះ ប៉ុន្តែការចូលរួមរបស់សិស្សរបស់អ្នក គឺមានសារៈសំខាន់ ដើម្បីស្វែងយល់ថាតើការអប់រំនៅសាលារៀនរបស់សិស្សរបស់អ្នកមានប្រសិទ្ធិភាពនៅក្នុងការអនុវត្តស្របតាមស្តង់ដារនៃការសិក្សាបានដល់កម្រិតណា។

- អ្នកផ្តល់ការអប់រំ និងអ្នកបង្កើតគោលនយោបាយប្រើប្រាស់ព័ត៌មានដែលទទួលបានពីការវាយតម្លៃនានាដែលត្រូវធ្វើការសម្រេចចិត្តអំពីធនធាន និងការគាំទ្រដែលត្រូវបានផ្តល់ជូន។
- ឪពុកម្តាយ និងសាធារណជនទូទៅប្រើប្រាស់ព័ត៌មាននៃការវាយតម្លៃដើម្បីធ្វើការប្រៀបធៀបរវាងសាលារៀនទាំងឡាយ និងធ្វើការសម្រេចចិត្តអំពីកន្លែងទិញផ្ទះ ឬកន្លែងចុះឈ្មោះចូលរៀនឲ្យកូនៗរបស់ពួកគេ។

ការគណនាប្រកបដោយគណនេយ្យភាពរបស់សាលារៀននឹងមានលក្ខណៈអវិជ្ជមានប្រសិនបើមានសិស្សានុសិស្សតិចជាង 95% ចូលរួមក្នុងការវាយតម្លៃនេះ។

*ទំនាក់ទំនងដ៏រឹងមាំទៅកាន់ស្តង់ដារនានាមានន័យថា "ការបង្រៀនដើម្បីធ្វើតេស្ត" គឺពិតជាផ្តោតលើស្តង់ដារនៃការសិក្សាដែលក្លាយជាផ្នែកមួយនៃការណែនាំប្រចាំថ្ងៃរួចហើយនោះ ពិតប្រាកដមែន។*

## តើខ្ញុំទទួលបានព័ត៌មានបន្ថែមនៅកន្លែងណា?

ស្វែងរកព័ត៌មានលម្អិតអំពីការធ្វើតេស្តទូទាំងរដ្ឋសម្រាប់សិស្សានុសិស្ស និងក្រុមគ្រួសារទាំងឡាយនៅលើ ទំព័រនៃការធ្វើតេស្តទូទាំងរដ្ឋនៃគេហទំព័ររបស់ MDE (education.state.mn.us > Students and Families > Statewide Testing).